ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០១៤

នៅក្នុងខែតុលានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម លើការដ្ឋានជាច្រើន ដោយផ្សារភ្ជាប់បទដ្ឋានការងាររដ្ឋបាល បច្ចេកទេស នីតិវិធី និងហិរញ្ញវត្ថុ ជាពិសេសការរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំវិសាមញ្ញព្រឹទ្ធសភា សិក្ខាសាលា ការងារចុះមូលដ្ឋាន ដំណើរការនីតិវិធីថ្លងគម្រោងថវិកាឆ្នាំ២០១៥ ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងសកម្មភាពការងារសង្គម និងខិតខំពង្រឹងពង្រីកភាពសុខដុមផ្ទៃក្នុង បង្កើនការសន្សំសំចៃខ្ពស់ បង្កើតសេវាថ្មីៗ កសាងគោលនយោបាយនានា បង្កើនកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

-បានចាត់ចែងរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន០២លើក ប្រជុំវិសាមញ្ញព្រឹទ្ធសភានីតិកាលទី៣ ចំនួន០១លើក សិក្ខាសាលា ស្តីពីទិវាវប្បធម៌ និងស្តីពីប្រវត្តិសាស្ត្រ និងបេតិកភណ្ឌខ្មែរ និងការវិវត្តនៃសេចក្តីព្រាងច្បាប់ ស្តីពីការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង ការប្រឡងប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ ជួបពិភាក្សាការងារជាមួយលេខាស្ថានទូតជប៉ុន ចូលរួមមហាសន្និបាតលើកទី១៣១ របស់សហភាពអន្តរសភា(IPU) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស និងចូលរួមប្រជុំពិភាក្សាការងារផ្សេងៗ ព្រមទាំងបានពិនិត្យសម្រេចលើឯកសារចំនួន៤០០ច្បាប់ ។

### ១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖

-បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការជំនាញ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ ចំនួន០៤ ។

### ២.សេវាទ្រទ្រង់មុខងារត្រួតពិនិត្យ៖

-បានអមដំណើរសមាជិក-សមាជិកា គណៈកម្មការទី១ និងទី៩ ព្រឹទ្ធសភា ចុះទៅត្រួតពិនិត្យអំពីការអនុវត្តសិទ្ធិមនុស្ស ជាពិសេសសិទ្ធិរបស់ជនជាតិដើមភាគតិច ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

និងច្បាប់នានា នៅខេត្តកំពង់ចាម ក្រចេះ និងខេត្តមណ្ឌលគិរី និងជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្ត និងមន្ទីរជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ស្ពឺ ។

**៣.សេវាទ្រទ្រង់មុខងារតំណាងៈ**

-បានរៀបចំវេទិកា ស្តីពីការបើកចំហព័ត៌មានសាធារណៈ ការដោះស្រាយបញ្ហារបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងសហគមន៍ក្នុងដំណើរឆ្ពោះទៅរកអភិបាលកិច្ចល្អ នៅព្រឹទ្ធសភា ។

-បានទទួលពាក្យបណ្តឹងចំនួន០៨ករណី និងបានឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន០១ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធបានចំនួន២០ករណី តម្កល់ទុកមិនចាត់ការចំនួន០១ករណី ។

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះទៅតាមបណ្តាខេត្តរាជធានីទូទាំងប្រទេស ចំនួន៧៨លើក ដើម្បីចុះជួបសំណេះសំណាល និងជួបពិភាក្សាការងារ សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អ នៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៣៦លើក ។

**៤.សេវាទ្រទ្រង់មុខងារព័ត៌មានៈ**

-បានអមដំណើរសមាជិក-សមាជិកា គណៈកម្មការទី ៥,ទី៦ និងទី៨ ព្រឹទ្ធសភា ចុះបំពេញបេសកកម្មទៅខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកែប ខេត្តកំពង់ឆ្នាំង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ដើម្បីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ថ្នាក់ដឹកនាំ និងមន្ត្រីនៃសាលាខេត្ត តុលាការ និងអយ្យការអមតុលាការខេត្ត សិក្សាស្វែងយល់អំពីការទប់ស្កាត់អំពើធ្វើអាជីវកម្មពលកម្មកុមារ អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងសំណេះសំណាល សិក្សាស្វែងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការផ្សព្វផ្សាយព័ត៌មាន។

-មន្ត្រីរាជការបានចុះបេសកកម្មចំនួន០៥លើក ដើម្បីស្រាវជ្រាវ និងប្រមូលព័ត៌មាន ស្តីពីការងារហិរញ្ញវត្ថុសង្កាត់, រៀបចំវេទិកាថ្នាក់ស្រុក, ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងចូលរួមក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់អណ្តូងទឹក ចំនួន០២កន្លែង នៅខេត្តកំពង់ធំ ព្រះវិហារ ស្វាយរៀង

កំពង់ស្ពឺ និងរាជធានីភ្នំពេញ ។

**៥.ការទំនាក់ទំនងអន្តរជាតិ៖**

-សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** អនុញ្ញាតឲ្យអគ្គរដ្ឋទូតវៀតណាម ចូលជួបសម្តែងការគួរសម ។

-ឯកឧត្តម **សាយ ឈុំ** អនុញ្ញាតឲ្យយុវជនអាស៊ានវ័យក្មេង ចំនួន២០នាក់ចូលជួបសម្តែងការគួរសម និងទៅបំពេញបេសកកម្ម នៅសាធារណរដ្ឋប្រជាមានិតចិន ។

-រៀបចំបែបបទជូនគណៈប្រតិភូព្រឹទ្ធសភា ទៅចូលរួមមហាសន្និបាតលើកទី១៣១ របស់សហភាពអន្តរសភា(IPU) នៅប្រទេសស្វីស ទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាមានិតចិន និងទស្សនកិច្ចសិក្សាស្វែងយល់ស្តីពីថវិកាឃុំ-សង្កាត់ និងសវនកម្មនៅឃុំ-សង្កាត់ នៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

-រៀបចំបែបបទជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅទស្សនកិច្ចសិក្សា ស្តីពីសហគមន៍សង្គម នៅប្រទេសជប៉ុន។

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិនានា (ឥណ្ឌា ប្រ៊ុយណេ ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ថៃ រុស្ស៊ី អាល្លឺម៉ង់ អូស្ត្រាលី ស្ថានកុងស៊ុលបែលហ្ស៊ិក ស្ថានកុងស៊ុលន័រវែស ) ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៦.ទំនាក់ទំនងសាធារណៈ៖**

-ទំនាក់ទំនងជាមួយស្ថានីយទូរទស្សន៍ជាតិ ទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ AEU, ECCC ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណជន ចូលអានសៀវភៅ ចំនួន២៥៧នាក់ ។

**៧.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០៣វគ្គ ស្តីពីភាសាអង់គ្លេសផ្ទៃក្នុង វគ្គភាសាចិន (ក្រុម២ ជំហាន៨ និងក្រុម១ ជំហាន៩) ។

-មន្ត្រីចំនួន០១រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការបំប៉នពង្រឹងសមត្ថភាព នៅប្រទេសវៀតណាម ។

**៨.ការអភិវឌ្ឍស្ថាប័ន៖**

-ការងារខាត់ម៉ាបរបស់អ្នកបច្ចេកទេសចិន នៅអគារជាជំនួយរបស់រដ្ឋាភិបាលចិន ជួសជុលខាត់លាប ពិដាន ស៊ុំឈើ និងបិទប្លាសស្ទិច នៅខុទ្ទកាល័យអគ្គលេខាធិការរងថ្មី ពិធីការសម្តេចប្រធាន

សាលបណ្ណាល័យ សាលពេញអង្គ និងនៅអគ្គនាយកដ្ឋានព័ត៌មានវិទ្យា ។

-ការងារធ្វើប្រទីបព្រឹទ្ធសភា ដើម្បីចូលរួមក្នុងពិធីបុណ្យអុំទូកអកអំបុកបណ្តែតប្រទីប និងសំពះព្រះខែ នាពេលខាងមុខ ។

**៩. ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ និងផ្សេងៗ**

-ចូលរួមទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនៈកោដ្ឋ ។

-ចូលរួមក្នុងព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិខួបលើកទី១០ របស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

-ចូលរួមពិធីសំណេះសំណាលទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ។

-រៀបចំការប្រឡងប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ ។

-ពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អនុវត្តវិន័យ និងរបបរាយការណ៍វត្តមានទៀងទាត់ប្រាកដប្រជា ។

-ចុះជំរឿនមន្ត្រីរាជការ ។

-ការតាំងស៊ប់ក្នុងមុខតំណែងជូនមន្ត្រីរាជការ ចំនួន១០៧រូប ។

-បានផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលស្តីពីវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងមធ្យមសម្រាប់ឆ្នាំសិក្សា២០១៤ នៅសាលាភូមិន្ទរដ្ឋបាល ។

-ពិនិត្យ និងវាយតម្លៃការអនុវត្តផែនការប្រតិបត្តិរយៈពេល០៩ខែ ។

-ប្រជុំស្តីពីផែនការយុទ្ធសាស្ត្រថវិកា០៣ឆ្នាំរំកិល ២០១៦-២០១៨ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ថវិកាកម្មវិធី អង្គភាពថវិកា ។

-ការងារចាត់តាំងពាក់ព័ន្ធអគ្គលេខាធិការរងថ្មី និងបុគ្គលិកបម្រើការនៅខុទ្ទកាល័យ ។

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន០៨លើក ។

-ថតចម្លងឯកសារ ចំនួន១៤៨សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន៣០ក្បាល ដោះស្រាយសំណើថវិកាចំនួន៣០៥សំណើ និងសម្ភារចំនួន៤៥សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន ១០៨លើក។

-ទទួលម៉ូតូខូចចំនួន០១គ្រឿង ប្រគល់ម៉ាស៊ីនព្រីនធ័រ កៅអីវិល ទូទឹកកក តុដែក និងក្តារខៀន ចំនួន១១គ្រឿង និងបិទលេខកូដតុដែក កៅអីវិល ទូទឹកកក និងម៉ាស៊ីនព្រីនធ័រ ចំនួន០៩គ្រឿង ។ បញ្ចូលហ្គាស ជួសជុលម៉ាស៊ីនត្រជាក់ បន្ទប់ទឹក ទូរស័ព្ទ ប្តូរអំពូលព្រី កុងតាក់ សោទ្វារ ចំនួន១១២គ្រឿង។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន៨៣គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន៦៦ប្រធានបទ ។

**II.ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០១៤**

**១.សេវាគ្រប់គ្រងមុខងារនីតិកម្ម៖**

-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំវិសាមញ្ញ ព្រឹទ្ធសភា ។

**២.សេវាគ្រប់គ្រងមុខងារត្រួតពិនិត្យ/ ព័ត៌មាន៖**

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ។

**៣.សេវាគ្រប់គ្រងមុខងារតំណាង៖**

-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភា តាមភូមិភាគ រួមទាំងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា ។

**៤.ការងារអន្តរជាតិ៖**

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា។

-គណៈប្រតិភូអនុប្រធានសភា ក្រុមប្រឹក្សាពិគ្រោះយោបល់ប្រជាជនចិន (ខែធ្នូ)

-ការពិគ្រោះយោបល់ខាងនីតិកម្មជាមួយKAS ។

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស រួមទាំងអគ្គលេខាធិការដ្ឋាន៖

-គណៈប្រតិភូកម្ពុជា ទៅទស្សនកិច្ចនៅប្រទេសបារាំង និងបែលហ្ស៊ិក ចូលរួមសិក្ខាសាលានៅប្រទេសថៃ និងឡាវ ។

-បន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង/ក្រៅប្រទេស សំរាប់ព្រឹទ្ធសភាតាមរយៈវិទ្យាស្ថានសភាកម្ពុជា ។

-ការចុះហត្ថលេខាលើឯកសារផ្តល់ជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលស៊ុយអែត

ស្វីស និងរដ្ឋសភាបារាំង ទន្ទឹមនឹងការងារPBO ជាមួយសហគមន៍អឺរ៉ុប និងធនាគារពិភពលោក។ ការដ្ឋានសហប្រតិបត្តិការជាមួយចិន និងវៀតណាម ទន្ទឹមនឹងសិក្សាលទ្ធភាពថ្មីជាមួយជប៉ុន ។

**៥.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-ជំរុញលើកកម្ពស់ចំណេះដឹងជំនាញភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ ការកត់ត្រាវត្តមាន និងសណ្តាប់ធ្នាប់សាធារណៈ សុខដុមកម្ម និងប្រក្រតីកម្ម ។

-ត្រៀមចូលរួមវគ្គសិក្សាអំពីអង្គភាពថវិកា និងចំណាយតាមកម្មវិធី ។

**៦.ការធានាផ្នែកសុខ សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-ត្រៀមធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៥ និងលើកទី៦ ។

-បន្តតាមដានគម្រោងថវិកា ឆ្នាំ២០១៩ របស់ព្រឹទ្ធសភា ដែលត្រូវឆ្លងរដ្ឋសភា និងព្រឹទ្ធសភា ។

-បន្តពង្រឹងពង្រីកការសិក្សាអំពីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។

-ត្រៀមរបាយការណ៍គ្រប់ថ្នាក់ប្រចាំឆ្នាំ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០១៨ និងគោលការណ៍ហិរញ្ញវត្ថុសំរាប់អនុវត្តឆ្នាំ២០១៩ ។

-ត្រៀមរៀបចំកែសម្រួលប្រព័ន្ធប្រាក់បៀវត្សថ្មីរបស់មន្ត្រីរាជការ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ត្រៀមរៀបចំបែបបទសុំគ្រឿងឥស្សរិយយសបំពាក់ជូនសមាជិកព្រឹទ្ធសភា ពាក់កណ្តាលនីតិកាលទី៣ ។

-ត្រៀមបំពាក់គ្រឿងឥស្សរិយយសដល់មន្ត្រីរាជការ ។

-បង្កើនសមត្ថភាពស្រាវជ្រាវឯកសារ ការចងបណ្តាញនាយកដ្ឋាន និងអង្គភាព និងចងក្រងទិន្នន័យបច្ចុប្បន្នភាពរបស់ជាតិ ដើម្បីពង្រឹងសមត្ថភាពស្រាវជ្រាវ និងផ្តល់សេវា ។

-ពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរបស់គ្រប់អង្គភាពអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំឆ្នាំ២០១៨ និងការរៀបចំផែនការប្រតិបត្តិឆ្នាំ២០១៩ ព្រមទាំងបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្ររបស់អគ្គលេខាធិការដ្ឋាន និងអគ្គនាយកដ្ឋានទាំង៣ ។

-ការជំរឿនធនធាន មធ្យោបាយ និងទ្រព្យសម្បត្តិ ការងារសំណង់/ ជួសជុលក្នុងពេលវិស្សមកាលព្រឹទ្ធសភា និងការកែលម្អឡើងវិញសួនច្បារ ។

-ការត្រៀមចូលរួមពិធីបុណ្យជាតិសំខាន់ៗរួមមាន៖

-បុណ្យឯករាជ្យជាតិ និងព្រះរាជពិធីបុណ្យអុំទូក អកអំបុក បណ្តែតប្រទីប និងសំពះព្រះខែ រួមទាំងទិវាសិទ្ធិមនុស្ស ១០ធ្នូ នាខែធ្នូខាងមុខ ។

-ត្រៀមរៀបចំបុណ្យកំណើតសម្តេចប្រធានព្រឹទ្ធសភា

-ត្រៀមសិក្ខាសាលាជាមួយKAF (ខែវិច្ឆិកា)

-ការត្រៀមប្រជុំអំពីនីតិវិធីអនុវត្តបទបញ្ជាផ្ទៃក្នុង

-ក្របខ័ណ្ឌយុទ្ធសាស្ត្រ១០ឆ្នាំរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋាន

-ត្រៀមការបោះពុម្ពដំណាច់ឆ្នាំ និងបញ្ចប់ការរៀបចំប្រទីប ។

**III.សេចក្តីសន្និដ្ឋាន**

ក្នុងខែតុលានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ បើកសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ និងសេចក្តីព្រាងច្បាប់ចំនួន០២ ។ ក្រៅពីការងារនីតិកម្ម ព្រឹទ្ធសភាផ្តោតលើការងារចុះមូលដ្ឋាន តាមរយៈបេសកកម្មចំនួន០៥លើក ការរៀបចំវេទិកាចំនួន០១លើក និងសិក្ខាសាលាចំនួន០២លើក ។ ដោយឡែកកិច្ចសហប្រតិបត្តិការអន្តរជាតិត្រូវបានពង្រឹងពង្រីក និងលើកកម្ពស់តាមរយៈការចូលរួមមហាសន្និបាតលើកទី១៣១ របស់សហភាពអន្តរសភា (IPU) នៅប្រទេសស្វីស និងការទទួលជំនួយថវិកាថ្មី សំរាប់វិទ្យាស្ថានសភាកម្ពុជា ។៚

ភ្នំពេញ, ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៤

**អគ្គលេខាធិការ**

អ៊ុំ សារិទ្ធ